ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៣៦៩......សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុលទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ត្រូវបានបង្កើត ក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ថា **ក.ប.ព.** ដើម្បីដឹកនាំសម្របសម្រួល និងជំរុញការកសាង និងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រកបដោយដវភាព សង្គតិភាព និងសុខដុមភាព សំដៅកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងចូលរួមចំណែកដល់ការកសាង និងអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា។

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់ ក.ប.ព

**ប្រការ២.-**

**ក.ប.ព.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- កំណត់ចក្ខុវិស័យ និងគោលការណ៍អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដឹកនាំ និងតម្រង់ទិសលើការរៀបចំផែនការមេ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីកសាង និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដឹកនាំ និងជំរុញការកសាងនិងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដឹកនាំ និងជំរុញការកសាងនិងការអភិវឌ្ឍភាពជាអ្នកដឹកនាំនិងអភិបាលកិច្ចឌីជីថលនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សម្រេច និងដាក់ឱ្យអនុវត្តស្តង់ដារបច្ចេកទេស ស្តង់ដារសន្តិសុខឌីជីថល ស្តង់ដារនីតិវិធីប្រតិបត្តិ និងសេចក្តីណែនាំបច្ចេកទេសបច្ចេកវិទ្យាព័ត៌មានផ្សេងៗ
- ដឹកនាំ សម្របសម្រួល និងដោះស្រាយការងារនិងបញ្ហាផ្សេងៗ ដែលមានលក្ខណៈអន្តរអង្គភាពពាក់ព័ន្ធនឹងគម្រោងបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កៀរគរធនធានហិរញ្ញវត្ថុ, ធនធានបច្ចេកទេស និងធនធានមនុស្ស ក្នុងបុព្វហេតុអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពិនិត្យ និងសម្រេចលើការស្នើសុំថវិកាគាំទ្រគម្រោងបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ជំរុញលើកទឹកចិត្ត និងគាំទ្រការចូលរួមលើកស្ទួយការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទីដីថល របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញតួនាទីនិងភារកិច្ចដទៃទៀត តាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៣

## សមាសភាព គ.ប.ព.

**ប្រការ៣.-**

**គ.ប.ព.**មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប | អនុប្រធានប្រចាំការ |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | អនុប្រធាន |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| - អនុរដ្ឋលេខាធិការពាក់ព័ន្ធមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - នាយកវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ប.ព.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ គ.ប.ព.

**ប្រការ៤.-**

អនុប្រធាននិងសមាជិក **គ.ប.ព.**ត្រូវចូលរួមកិច្ចប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។

ក្នុងករណីអវត្តមានឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធាន ឬអនុប្រធានប្រចាំការ ឱ្យកោះ-អញ្ជើញ និងដឹកនាំកិច្ចប្រជុំ។

**ប្រការ៥.-**

**គ.ប.ព**មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងការបំពេញតួនាទីនិងភារ-កិច្ចរបស់ខ្លួន។

**ប្រការ៦.-**

**គ.ប.ព.** មានក្រុមការងារបច្ចេកទេសមួយជាសេនាធិការ នៅក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។

ក្រុមការងារបច្ចេកទេស **គ.ប.ព.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - អនុប្រធានប្រចាំការនៃ **គ.ប.ព.** | ប្រធាន |

- ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គលេខាធិការដ្ឋានក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ — អនុប្រធានប្រចាំការ
- ប្រធានអង្គភាព ឬអនុប្រធានប្រចាំការទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន នៃអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយចំនួន — អនុប្រធាន
- ប្រធាននាយកដ្ឋានទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាន នៃអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក
- តំណាងក្រុមការងារទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក។

សមាសភាពជាក់ស្តែងនៃក្រុមការងារបច្ចេកទេស **ក.ប.ព.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៧.-**

ក្រុមការងារបច្ចេកទេស **ក.ប.ព.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- សម្របសម្រួលលើការងារអនុវត្តផែនការមេ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីកសាងនិងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សហការការងារជាមួយនឹងអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពាក់ព័ន្ធការកសាងនិងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កសាង អភិវឌ្ឍ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងថ្នាលឌីជីថលសម្រាប់ការប្រើប្រាស់រួម
- រៀបចំស្តង់ដារបច្ចេកទេស ស្តង់ដារសន្តិសុខឌីជីថល ស្តង់ដារនីតិវិធីប្រតិបត្តិ និងសេចក្តីណែនាំបច្ចេកទេសបច្ចេកវិទ្យាព័ត៌មានផ្សេងៗ
- ផ្តួចផ្តើម និងកំណត់កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ និងរៀបចំទស្សនកិច្ចសិក្សាទាំងក្នុងប្រទេស និងក្រៅប្រទេស ដើម្បីទាញយកបទពិសោធន៍និងប្រមូលធាតុចូលសំខាន់ៗពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល
- រៀបចំឱ្យមានការបណ្តុះបណ្តាល ការពង្រឹងសមត្ថភាព និងការចែករំលែកចំណេះដឹងទៅលើការអភិវឌ្ឍ ការប្រតិបត្តិ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលនានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំផែនការវិនិយោគ ដើម្បីគាំទ្រដល់ការអនុវត្តផែនការមេបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល
- ពិនិត្យ ពិភាក្សា វាយតម្លៃ និងធ្វើអាទិភាពូបនីយកម្មគម្រោងបច្ចេកវិទ្យាព័ត៌មានដែលបានស្នើក្នុងក្របខណ្ឌការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពនៃថវិកា និងសង្គតិភាពជាមួយផែនការមេបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការមេ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយត្រូវរៀបចំរបាយការណ៍ជូន **ក.ប.ព.**

- បំពេញតួនាទីនិងភារកិច្ចដទៃទៀត តាមការប្រគល់របស់ប្រធានក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨.-**

ក្រុមការងារបច្ចេកទេស **ក.ប.ព.** មាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន។ លេខាធិការដ្ឋានក្រុមការងារបច្ចេកទេស **ក.ប.ព.** បំពេញមុខងារជាសេនាធិការជូនក្រុមការងារបច្ចេកទេស **ក.ប.ព.** លើការងាររដ្ឋបាល និងបច្ចេកទេស។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



តេលេក្រាម - ឯកសារមន្ត្រីសាធារណៈ